# ការយល់ដឹងអំពីកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

នាងខ្ញុំឈ្មោះ ស៊ុន ដាណេ ជានិស្សិតឆ្នាំទី៣ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកប្រវត្តិវិទ្យា។ នាងខ្ញុំមានស្រុកកំនើតនៅភូមិពង្រ ឃុំកណ្តោលជុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ។

បន្ទាប់ពីនាងខ្ញុំបានស្តាប់កម្មវិធីវិទ្យុសហគមន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្សព្វផ្សាយអំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅរបបខ្មែរក្រហមរួចមក នាងខ្ញុំ ពិតជាមានចំណាប់អារម្មណ៍ ចំពោះកម្មវិធីវិទ្យុនេះ។ ក្នុងនាមខ្ញុំជានិស្សិតប្រវត្តវិទ្យា ខ្ញុំពិតជាមានសេចក្តីពេញចិត្តចំពោះការផ្សព្វផ្សាយអំពីរឿងរ៉ាវអតីតកាលដ៏ជូរចត់ ការប្រល័យពូជសាសន៍យ៉ាងឃោឃៅ និងការអត់ឃ្លាននៅរបបខ្មែរក្រហម ដែលកម្មវិធីវិទ្យុសហគមន៍មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្សព្វផ្សាយជាសាធារណៈ។ ក្នុងការស្តាប់កម្មវិធីវិទ្យុសហគមន៍នេះរួចមក នាងខ្ញុំទទួលបានចំនេះដឹង និងមានការយល់ដឹងអំពីបញ្ហាជាច្រើនទាក់ទង និងការប្រល័យពូជសាសន៍នៅប្រទេសប៉ូឡូញក្នុងសង្គ្រាមលោកលើកទី២ និងការប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា នៅក្នុងរបបខ្មែរក្រហម ក្នុងឆ្នាំ១៩៧៥ ដល់១៩៧៩។ ទាក់ទងនិងការប្រល័យពូជសាសន៍ មេដឹកនាំក្នុងរបបនេះ បានធ្វើទុកបុកម្នេញឲ្យប្រជាពលរដ្ឋជាច្រើននៅក្នុងប្រទេសទទួលរងទុក្ខវេទនាជាខ្លាំង។ ដោយសារការប្រល័យពូជសាសន៍នេះ បានធ្វើឲ្យប្រជាពលរដ្ឋទទួលរងនូវការឈឺចាប់ជាច្រើន មិនមានការផ្តល់សិទ្ធមនុស្សក្នុងការរស់នៅមានភាពអត់ឃ្លាន បង្ខំឲ្យប្រជាជនធ្វើការងារធ្ងន់ធ្ងរ និងមានការកាប់សម្លាប់

យ៉ាងព្រៃផ្សៃទៅលើប្រជាជនស្លូតត្រង់គ្មានត្រាប្រណីក្នុងរបបខ្មែរក្រហម នៅប្រទេសកម្ពុជាក៏ដូចជាប្រទេសប៉ូឡូញផងដែរ។ លើសពីនេះទៅទៀត ខ្ញុំបានយល់ដឹងអំពីការអត់ឃ្លានរបស់ប្រជាពលរដ្ឋ ឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ និងសិទ្ធមនុស្សក្នុងការទទួលបានអាហារគ្រប់គ្រាន់។

សរុបសេចក្តីមកក្នុងនាមខ្ញុំជាកូនខ្មែរមួយរូប នាងខ្ញុំពិតជាមានអារម្មណ៍សោកស្តាយចំពោះការកើតមានឡើងនូវអំពើប្រល័យពូជសាសន៍ដែលកើតមានឡើងក្នុងប្រទេសកម្ពុជានិងប្រទេសប៉ូឡូញផងដែរ។ ជាពិសេសចំពោះការអត់ឃ្លាន និងការរំលោភសិទ្ធមនុស្សចំពោះប្រជាពលរដ្ឋ។ ដូចនេះក្នុងនាមខ្ញុំជានិស្សិតមួយរូប នាងខ្ញុំនិងខិតខំផ្សព្វផ្សាយចំនេះដឹងដែលទាក់ទង និងអំពើប្រល័យពូជសាសន៍នេះដល់ប្រជាពលរដ្ឋឲ្យបានយល់ច្បាស់។ នាងខ្ញុំនិងរក្សាការចងចាំអំពីរឿងរ៉ាវអតីតកាលទាំងអស់នេះទុក ដើម្បីប្រាប់ក្មេងជំនាន់ក្រោយឲ្យបានដឹង និងរកវិធីបែបណាដើម្បីកុំឲ្យអំពើប្រល័យពូជសាសន៍នេះកើតមានឡើងនៅក្នុងប្រទេសកម្ពុជាសារជាថ្មី។

## My Personal Impression on DC-Cam Community Radio[1]

My name is Sun Dane. I am a third year university student of Royal University of Phnom Penh majoring in history. My hometown is located in Pongror Village, Kondoal Dom Commune, Chbarmorn District, Kompong Speu Province.

After I listened to DC-Cam's Community Radio Program, which broadcasts about the genocide and the starvation that happened in the Khmer Rouge regime, I am really interested in this radio program. Because I am a history student, I really love it and listen with enthusiasm to the broadcast about the sad stories in the past, the harsh genocide and the starvation during Khmer Rouge regime. After listening to this radio program, I gained more knowledge and understanding about a lot of problems that relates to the genocide in Poland in World War II and genocide in Cambodia in the Khmer Rouge regime between 1975 and 1979. Related to the genocide, the top leaders in this regime irritated a lot of citizens who suffered so much. Because of this genocide, a lot of citizens suffered and were living with no rights, faced starvation, forced to labor and were cruelly killed in Khmer Rouge regime in Cambodia and Poland as well. Furthermore, I understand about citizens who faced starvation, the crimes against humanity and the rights for people to have sufficient food.

In short, as a Cambodian youth, I really regret that genocide happened in Cambodia and Poland, especially with those who faced starvation and their rights taken away. As a university student, I will try to broadcast my knowledge that relates genocide to all citizens more clearly. I will remember all these past memories in order to tell the next younger generation and try to prevent it from taking place in Cambodia again.

[1] Translated by Lorn Dalin; edited by Sreyneath Poole